# CITY OF SIGNAL HILL.

2175 Cherry Avenue ◆ Signal Hill, California 90755-3799

## <u>សេចក្តីជូនដំណឹងស្តីពីការបោះឆ្នោត</u>

**សេចក្តីជូនដំណឹងនេះត្រូវបានប្រកាសដោយបង្ហាញថា** ការបោះឆ្នោតសាលាក្រុងទូទៅនឹងត្រូវបានប្រារព្ធធ្វើឡើងនៅក្នុង City of Signal Hill នាថ្ងៃអង្គារ ទី 3 ខែវិច្ឆិកា ឆ្នាំ 2020 សម្រាប់មុខតំណែងដូចខាងក្រោម៖

សមាជិកក្រុមប្រឹក្សាក្រុងបីរូប ពេញអាណត្តិចំនួនបួនឆ្នាំ

រយៈពេលតែងតាំងសម្រាប់មុខតំណែងទាំងនេះនឹងចាប់ផ្តើមនៅថ្ងៃច័ន្ទ ទី 13 ខែកក្កដា ឆ្នាំ 2020 វេលាម៉ោង 7:30 នាទីព្រឹក ហើយបិទនៅថ្ងៃសុក្រ ទី 7 ខែសីហា ឆ្នាំ 2020 វេលាម៉ោង 4:30 នាទីល្ងាច ។

ប្រសិនបើឯកសារតែងតាំងសំរាប់មន្ត្រីកាន់តំណែងទីក្រុងមិនត្រូវបានដាក់ត្រឹមថ្ងៃសុក្រ ទី 7 ខែសីហា ឆ្នាំ 2020 (ថ្ងៃទី 88 មុនការបោះឆ្នោត) នោះអ្នកបោះឆ្នោតគប្បីមានសិទ្ធិរហូតដល់ថ្ងៃទី 83 មុនការបោះឆ្នោត ពោលគឺថ្ងៃពុធទី 12 ខែសីហា ឆ្នាំ 2020 ដើម្បីតែងតាំងបេក្ខជនផ្សេងទៀតក្រៅពីបុគ្គលដែលកាន់តំណែងនៅថ្ងៃទី 88 មុនការបោះឆ្នោតសម្រាប់មុខតំណែងបោះឆ្នោតជ្រើសរើសអ្នកកាន់តំណែងនោះ ។ ផ្នែកបន្ថែមនេះមិនអាចអនុវត្តបានទេ ប្រសិនបើមិនមានអ្នកកំពុងកាន់តំណែងដែលនឹងត្រូវបានបោះឆ្នោតជ្រើសរើសនោះ ។

ប្រសិនបើគ្មាននរណាម្នាក់ ឬមានបុគ្គលតែម្នាក់គត់ត្រូវបានគេជ្រើសរើសសម្រាប់មុខតំណែងបោះឆ្នោតជ្រើសរើស នោះការតែងតាំងមុខតំណែងបោះឆ្នោតជ្រើសរើសអាចធ្វើឡើងតាមបទបញ្ញត្តិដែលកំណត់ដោយ § 10229, ក្រមបោះឆ្នោតនៃរដ្ឋ California ។

មណ្ឌលបោះឆ្នោតនឹងត្រូវបើកចំហអោយប្រើប្រាស់តាមតំរូវការក្នុងកំឡុងពេលបោះឆ្នោតដែលបានកំនត់ដោយអនុលោមតាមផ្នែក 4007 និង 14401 នៃក្រមបោះឆ្នោត ។ មណ្ឌលបោះឆ្នោតអាចរកបាននៅ www.lavote.net ។

Carmen R. Brooks
ស្មៀនក្រុង

បានបោះពុម្ពផ្សាយ ៖ ថ្ងៃទី 10 ខែកក្កដា ឆ្នាំ 2020

បានបិទផ្សាយនៅសាលាក្រុង, Discovery Well Park, Reservoir Park, បណ្ណាល័យ Signal Hill និងនៅលើគេហទំព័រសាលាទីក្រុងនៅថ្ងៃ ឬមុន ថ្ងៃទី 10 ខែកក្កដា ឆ្នាំ 2020